# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ.៥៤៩..........ប្រក.កសក

អគ្គនាយកដ្ឋាន
សុខភាពសត្វ និងផលិតកម្មសត្វ
ចូល
លេខ: 1413
ថ្ងៃទី: 20 -12-18
ម៉ោង:

# ប្រកាស
## ស្តីពី
## ចំណាត់ថ្នាក់ខ្នាត បទដ្ឋានបច្ចេកទេស និងនីតិវិធី សម្រាប់ការផ្តល់លិខិតអនុញ្ញាតការចិញ្ចឹមសត្វនិងការបង្កាត់ពូជសត្វ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/០០៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៀវត្រសាស្ត្រនិងកែលម្អដីកសិកម្មទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្ដីពីការដំឡើងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញប្រកាសរួមលេខ១០១៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញប្រកាសលេខ០៥១ ប្រក.កសក ចុះថ្ងៃអង្គារ ១៥រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨ ស្ដីពីនីតិវិធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែម
- បានឃើញប្រកាសលេខ២០៨ ប្រក.កសក ចុះថ្ងៃពុធ ១១កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨ ស្ដីពីនីតិវិធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីបសុឱសថ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីការបង្កើត ការគ្រប់គ្រង ចំណាត់ថ្នាក់ខ្នាត បទដ្ឋានបច្ចេកទេស និងនីតិវិធីសម្រាប់ការផ្ដល់លិខិតអនុញ្ញាតការចិញ្ចឹមសត្វនិងការបង្កាត់ពូជសត្វ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅ ៖

- លើកកម្ពស់ការគ្រប់គ្រងធនធានសេនេទិកសត្វប្រកបដោយនិរន្តរភាព
- បង្កើនផលិតភាពសត្វ
- ធានានូវផលិតកម្មសត្វមានអនាម័យ
- ធានានូវផលិតផលសត្វមានគុណភាព សុវត្ថិភាព
- បង្ការទប់ស្កាត់ការរីករាលដាលជំងឺឆ្លងសត្វ និងជំងឺស៊ូណូស
- ការពារសុខភាពសត្វ សុខុមាលភាពសត្វ សុខភាពសាធារណៈ និងបរិស្ថាន។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការចិញ្ចឹមសត្វ និងការបង្កាត់ពូជសត្វ នៅតាមទីកន្លែង ឬកសិដ្ឋានចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**ប្រការ ៤.-**

ការបង្កើត ការគ្រប់គ្រង និងការត្រួតពិនិត្យអនាម័យទីកន្លែង ឬកសិដ្ឋានចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វ ត្រូវស្ថិតក្រោមដែនសមត្ថកិច្ចរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល។

## ជំពូកទី៣
## ចំណាត់ថ្នាក់ខ្នាត និងបទដ្ឋានបច្ចេកទេស
## សម្រាប់ការចិញ្ចឹមសត្វនិងការបង្កាត់ពូជសត្វ

**ប្រការ ៥.-**

ការចិញ្ចឹមសត្វ និងការបង្កាត់ពូជសត្វ ត្រូវបានកំណត់ដូចខាងក្រោម ៖

ក/. ការចិញ្ចឹមសត្វ ឬការបង្កាត់ពូជសត្វជាលក្ខណៈពាណិជ្ជកម្ម

ខ/. ការចិញ្ចឹមសត្វ ឬការបង្កាត់ពូជសត្វជាលក្ខណៈគ្រួសារ ឬលក្ខណៈប្រពៃណី ដើម្បីបម្រើជីវភាពប្រចាំថ្ងៃ។

**ប្រការ ៦.-**

ការចិញ្ចឹមសត្វ និងការបង្កាត់ពូជសត្វជាលក្ខណៈពាណិជ្ជកម្មត្រូវបានចាត់ថ្នាក់ខ្នាតដូចខាងក្រោម ៖

ក/. ខ្នាតតូច

ខ/. ខ្នាតមធ្យម

គ/. ខ្នាតធំ។

ចំណាត់ថ្នាក់ខ្នាត និងបទដ្ឋានបច្ចេកទេសសម្រាប់ការបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វជាលក្ខណៈពាណិជ្ជកម្មត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

## ជំពូកទី៤
## នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត
## សម្រាប់ការចិញ្ចឹមសត្វនិងការបង្កាត់ពូជសត្វ

**ប្រការ ៧.-**

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានបំណងបង្កើតកសិដ្ឋានចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វជាលក្ខណៈពាណិជ្ជកម្មត្រូវអនុវត្តតាមលក្ខខណ្ឌតម្រូវដូចខាងក្រោម ៖

- កសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វស្ថិតនៅទីតាំងមួយសមស្រប
- ត្រូវគោរពតាមបទដ្ឋានបច្ចេកទេសបសុព្យាបាល
- ត្រូវមានប្រព័ន្ធជីវសុវត្ថិភាព និងការគ្រប់គ្រងកាកសំណល់
- មិនត្រូវប្រើប្រាស់បសុឱសថឬចំណីសត្វដែលមានសារធាតុហាមឃាត់ សារធាតុគ្រោះថ្នាក់ សារធាតុជំរុញការលូតលាស់របស់សត្វខុសប្រក្រតី ប្រើប្រាស់អង់ទីប៊ីយូទិកលើសការកំណត់ ឬប្រើផលិតផលសារពាង្គកាយរស់កែច្នៃសេនេទិកហាមឃាត់ ដែលបង្កគ្រោះថ្នាក់ដល់សុខភាពសត្វ និងមនុស្ស
- មានអនាម័យល្អ មិនមានក្លិន និងសំឡេងប៉ះពាល់ដល់បរិស្ថាន។

**ប្រការ ៨.-**

ការបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វគ្រប់ប្រភេទជាលក្ខណៈពាណិជ្ជកម្មត្រូវមានលិខិតអនុញ្ញាត។

ចំពោះទីតាំងសម្រាប់ការបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វគ្រប់ប្រភេទជាលក្ខណៈពាណិជ្ជកម្មត្រូវចុះទិដ្ឋាការពីអាជ្ញាធរដែនដី។

លិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ ត្រូវផ្តល់ដោយ ៖

ក- អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ចំពោះកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វខ្នាតមធ្យម និងខ្នាតធំ ក្រោយទទួលបានគោលការណ៍អនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ខ- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំពោះកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ ខ្នាតតូច តាមសំណើរបស់ការិយាល័យផលិតកម្ម និងបសុព្យាបាល រាជធានី ខេត្តសាមី ដោយមានការឯកភាពជាគោលការណ៍ផ្នែកបច្ចេកទេសពីអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

គំរូសំណុំបែបបទសម្រាប់ការស្នើសុំលិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ និងគំរូលិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វជាលក្ខណៈពាណិជ្ជកម្ម ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ ៩.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលស្នើសុំបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ ត្រូវដាក់ពាក្យសុំនៅអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលបានលិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វត្រូវចុះបញ្ជីកសិដ្ឋាននោះ នៅអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ស្របតាមនីតិវិធីជាធរមាន។

គំរូពាក្យស្នើសុំ និងគំរូវិញ្ញាបនបត្រចុះបញ្ជីកសិដ្ឋានចិញ្ចឹមសត្វ និង/ឬបង្កាត់ពូជសត្វជាលក្ខណៈពាណិជ្ជកម្មត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។

**ប្រការ ១០.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលស្នើសុំវិញ្ញាបនបត្របញ្ជាក់ការអនុវត្តការចិញ្ចឹមសត្វល្អ (GAHP) សម្រាប់កសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វជាលក្ខណៈពាណិជ្ជកម្មត្រូវដាក់ពាក្យសុំនៅអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

គំរូពាក្យស្នើសុំ និងគំរូវិញ្ញាបនបត្របញ្ជាក់ការអនុវត្តការចិញ្ចឹមសត្វល្អ (GAHP) សម្រាប់កសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វជាលក្ខណៈពាណិជ្ជកម្មត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី៤ នៃប្រកាសនេះ។

**ប្រការ ១១.-**

ការចិញ្ចឹមសត្វ និងការបង្កាត់ពូជសត្វជាលក្ខណៈគ្រួសារ ឬជាលក្ខណៈប្រពៃណីមិនតម្រូវឲ្យមានលិខិតអនុញ្ញាតឡើយ ប៉ុន្តែត្រូវស្ថិតក្រោមការគ្រប់គ្រងបច្ចេកទេសពីអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល។

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវរៀបចំគោលការណ៍ណែនាំ និងបទដ្ឋានបច្ចេកទេសសមស្របសម្រាប់ការគាំទ្រដល់ការចិញ្ចឹមសត្វ និងការបង្កាត់ពូជសត្វជាលក្ខណៈគ្រួសារ ឬជាលក្ខណៈប្រពៃណីនេះ។

**ប្រការ ១២.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានទទួលការអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វ និងបានចុះបញ្ជីរួចហើយ ត្រូវអនុវត្តតាមលក្ខខណ្ឌតម្រូវដូចខាងក្រោម ៖

- បង្កភាពងាយស្រួលដល់មន្ត្រីជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល មានសមត្ថកិច្ចក្នុងការត្រួតពិនិត្យអនាម័យ យកសំណាកសម្រាប់ការធ្វើវិភាគ ឬអនុវត្តវិធានបសុព្យាបាល ក្នុងកសិដ្ឋានចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វ ក្នុងករណីចាំបាច់
- គោរពតាមបទដ្ឋានបច្ចេកទេសដែលមានចែងក្នុងកិច្ចសន្យាស្ដីពីការបង្កើតកសិដ្ឋានចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វ
- ផ្ដល់របាយការណ៍ទៀងទាត់ជូនអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល រួមមានផែនការផលិតកម្ម ស្ថិតិសត្វចិញ្ចឹម និងស្ថានភាពជំងឺសត្វ នៅរៀងរាល់៣(បី)ខែម្ដង
- អនុញ្ញាតឲ្យចុះធ្វើការសិក្សាស្រាវជ្រាវដកស្រង់បទពិសោធន៍ និងធ្វើកម្មសិក្សាលើការងារបច្ចេកទេស។

ក្រោយពីទទួលបានការអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ និង/ឬបង្កាត់ពូជសត្វ រូបវន្តបុគ្គល ឬនីតិបុគ្គលនោះត្រូវធ្វើកិច្ចសន្យាស្ដីពីការគ្រប់គ្រងបច្ចេកទេសកសិដ្ឋានចិញ្ចឹមសត្វ និង/ឬបង្កាត់ពូជសត្វជាមួយអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល។

**ប្រការ ១៣.-**

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលស្នើសុំបង្កើតកសិដ្ឋានចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វ ត្រូវបង់សោហ៊ុយសេវាកម្មជាមុននៅអង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ដោយផ្អែកលើប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ១៤.-**

លិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វ មានសុពលភាពរយៈពេល៥(ប្រាំ)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាត លើកលែងតែមានការព្យួរ ឬដកហូតដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

រូបវន្តបុគ្គល ឬនីតិបុគ្គលត្រូវស្នើសុំជាថ្មីនូវលិខិតអនុញ្ញាត ក្នុងរយៈពេល៦(ប្រាំមួយ)ខែ មុនកាលបរិច្ឆេទផុតសុពលភាព។ ក្នុងករណីខកខានក្នុងការស្នើសុំជាថ្មី លិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វនោះ ត្រូវនិរាករណ៍ដោយស្វ័យប្រវត្តិនូវកាលបរិច្ឆេទផុតសុពលភាព។

## ជំពូកទី៥
## ទោសប្បញ្ញត្តិ

**ប្រការ ១៥.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រព្រឹត្តល្មើស ឬមិនគោរពតាមនីតិវិធី បទប្បញ្ញត្តិ និងបទដ្ឋានបច្ចេកទេសសម្រាប់ការចិញ្ចឹមសត្វ និងការបង្កាត់ពូជសត្វ ដូចមានចែងក្នុងប្រកាសនេះ ត្រូវទទួលទណ្ឌកម្មជាក់លាក់ដោយអនុលោមតាមទោសប្បញ្ញត្តិដូចមានចែងក្នុងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ ១៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៧.-**

អគ្គលេខាធិការ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ៥ កើត ខែ មិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាក់ព័ន្ធ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ ១៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

លេខៈ១៤៦២សផស

បានចតចម្លងត្រឹមត្រូវតាមច្បាប់ដើម នូវប្រកាសលេខ៥៤៩ ប្រក. កសក ចុះថ្ងៃពុធ ៥កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ និងបញ្ជូនមកៈ

- លោក លោកស្រីអគ្គនាយករង
- លោកប្រធានគ្រប់នាយកដ្ឋាន និងលោកនាយកវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ ក្រោមឱវាទអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទាំង ២៥ រាជធានី-ខេត្ត
- លោកប្រធានការិយាល័យផលិតកម្ម និងបសុព្យាបាល ទាំង២៥ រាជធានី-ខេត្ត

"ដើម្បីជ្រាប និងអនុវត្ត"

- ឯកសារ កាលប្បវត្តិ

ថ្ងៃអង្គារ ៣រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**

**អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ**

តាន់ ផាន់ណារ៉ា

ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ.៥៤៨..........ប្រក.កសក ចុះថ្ងៃទី...១៧....ខែ....៥.........ឆ្នាំ២០១៨

ស្តីពី "**ចំណាត់ថ្នាក់ខ្នាត បទដ្ឋានបច្ចេកទេស និងនីតិវិធី**
**សម្រាប់ការផ្តល់លិខិតអនុញ្ញាតការចិញ្ចឹមសត្វនិងការបង្កាត់ពូជសត្វ**"

# ចំណាត់ថ្នាក់ខ្នាត និងបទដ្ឋានបច្ចេកទេស
# សម្រាប់ការចិញ្ចឹមសត្វ និងការបង្កាត់ពូជសត្វជាលក្ខណៈពាណិជ្ជកម្ម

## ក-ខ្នាតតូច

### ក.១. ប្រភេទសត្វ និងចំនួនសត្វ

**១.១. គោ ក្របី**

១.១.១. គោ ក្របីយកសាច់ ៖ ចាប់ពី១០០(មួយរយ)ក្បាល ដល់តិចជាង៣០០(បីរយ)ក្បាល

១.១.២. គោ ក្របីយកទឹកដោះ ៖ មេចាប់ពី២០(ម្ភៃ)ក្បាល ដល់តិចជាង១០០(មួយរយ)ក្បាល

**១.២. សេះ**

១.២.១ សេះគ្រប់ប្រភេទ ៖ ចាប់ពី២០(ម្ភៃ)ក្បាល ដល់តិចជាង១០០(មួយរយ)ក្បាល

**១.៣. ជ្រូក**

១.៣.១. ជ្រូកយកសាច់ ៖ ចាប់ពី១០០ (មួយរយ) ក្បាល ដល់តិចជាង១.០០០ (មួយពាន់)ក្បាល

១.៣.២. ជ្រូកពូជ ៖ មេ បា ចាប់ពី៥០(ហាសិប)ក្បាល ដល់តិចជាង២០០(ពីរយ)ក្បាល

**១.៤. ពពែ**

១.៤.១. ពពែគ្រប់ប្រភេទ ៖ ចាប់ពី៣០០(បីរយ)ក្បាល ដល់តិចជាង១.០០០(មួយពាន់)ក្បាល

**១.៥. ចៀម**

១.៥.១. ចៀមគ្រប់ប្រភេទ ៖ ចាប់ពី៣០០(បីរយ)ក្បាល ដល់តិចជាង១.០០០(មួយពាន់)ក្បាល

**១.៦. ស្វា**

១.៦.១. ស្វាគ្រប់ប្រភេទ ៖ ចាប់ពី១០០ (មួយរយ) ក្បាល ដល់តិចជាង១.០០០ (មួយពាន់)ក្បាល

**១.៧. ទន្សាយ**

១.៦.១. ទន្សាយគ្រប់ប្រភេទ ៖ ចាប់ពី១០០ (មួយរយ) ក្បាល ដល់តិចជាង១.០០០ (មួយពាន់)ក្បាល

**១.៨. សត្វស្លាប**

១.៨.១. មាន់យកស៊ុត ៖ ចាប់ពី២.០០០(ពីរពាន់)ក្បាល ដល់តិចជាង២០.០០០(ពីរម៉ឺន)ក្បាល

១.៨.២. មាន់យកសាច់ ៖ ចាប់ពី៥.០០០(ប្រាំពាន់)ក្បាល ដល់តិចជាង៣០.០០០(បីម៉ឺន)ក្បាល

១.៨.៣. មាន់ពូជ ៖ មេ បា ចាប់ពី១.០០០(មួយពាន់)ក្បាល ដល់តិចជាង៥.០០០(ប្រាំពាន់)ក្បាល

១.៨.៤. ទា ៖ ចាប់ពី៥.០០០(ប្រាំពាន់)ក្បាល ដល់តិចជាង២០.០០០(ពីរម៉ឺន)ក្បាល

១.៨.៥. ក្រួច ៖ ចាប់ពី១០.០០០(មួយម៉ឺន)ក្បាល ដល់តិចជាង៥០.០០០(ប្រាំម៉ឺន)ក្បាល

**១.៩. ឃ្មុំ**

១.៩.១. ឃ្មុំគ្រប់ប្រភេទ ៖ ចាប់ពី១០០ (មួយរយ) សំបុក ដល់តិចជាង៥០០ (ប្រាំរយ)សំបុក

**ក.២. លក្ខខណ្ឌបច្ចេកទេស**

**២.១ ទីកន្លែង ឬកសិដ្ឋានចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វ**

- មិនត្រូវនៅជិតប្រភពទឹក ឬកន្លែងងាយរងគ្រោះដោយទឹកជំនន់
- មានរបងព័ទ្ធជុំវិញកន្លែងចិញ្ចឹម
- មិនត្រូវស្ថិតនៅជិតសាលារៀន ទីប្រជុំជន ទីកន្លែងសាសនាផ្សេងៗ មន្ទីរពេទ្យ ផ្សារ សត្តឃាតដ្ឋាន ឬកន្លែងពិឃាតសត្វ
- កន្លែងចិញ្ចឹមមានប្រព័ន្ធខ្យល់ចេញ ចូលបានល្អ

**២.២ ចំណី និងទឹក**

- ផ្តល់ចំណីមានគុណភាពល្អ
- ហាមប្រើបសុឱសថ ឬចំណីសត្វដែលមានសារធាតុហាមឃាត់ សារធាតុគ្រោះថ្នាក់ សារធាតុជំរុញការលូតលាស់ខុសប្រក្រតី ឬប្រើផលិតផលសារពាង្គកាយរស់កែច្នៃសេនេទិកហាមឃាត់ ដែលបង្កគ្រោះថ្នាក់ដល់សុខភាពសត្វ និងមនុស្ស
- ផ្តល់ទឹកស្អាត មានគុណភាព និងអនាម័យ។

**២.៣ អនាម័យក្នុងកន្លែងចិញ្ចឹម**

- កន្លែងចិញ្ចឹមមានអនាម័យស្របតាមបទដ្ឋានបច្ចេកទេសកំណត់ដោយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

**២.៤ ការគ្រប់គ្រងកាកសំណល់**

- អនុវត្តតាមបទដ្ឋានបច្ចេកទេសស្តីពីការគ្រប់គ្រងកាកសំណល់របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

## ខ-ខ្នាតមធ្យម

**ខ.១. ប្រភេទសត្វ និងចំនួនសត្វ**

**១.១. គោ ក្របី**

១.១.១. គោ ក្របីយកសាច់ ៖ ចាប់ពី៣០០(បីរយ)ក្បាល ដល់តិចជាង១.០០០(មួយពាន់)ក្បាល

១.១.២. គោ ក្របីយកទឹកដោះ ៖ មេចាប់ពី១០០(មួយរយ)ក្បាល ដល់តិចជាង៣០០(បីរយ)ក្បាល

**១.២. សេះ**

១.២.១ សេះគ្រប់ប្រភេទ ៖ ចាប់ពី១០០(មួយរយ)ក្បាល ដល់តិចជាង៥០០(ប្រាំរយ)ក្បាល

**១.៣. ជ្រូក**

១.៣.១. ជ្រូកយកសាច់ ៖ ចាប់ពី១.០០០(មួយពាន់)ក្បាល ដល់តិចជាង៥.០០០(ប្រាំពាន់)ក្បាល

១.៣.២. ជ្រូកពូជ ៖ មេ បា ចាប់ពី២០០(ពីររយ)ក្បាល ដល់តិចជាង៥០០(ប្រាំរយ)ក្បាល

**១.៤. ពពែ**

១.៤.១. ពពែគ្រប់ប្រភេទ ៖ ចាប់ពី១.០០០(មួយពាន់)ក្បាល ដល់តិចជាង៥.០០០(ប្រាំពាន់)ក្បាល

**១.៥. ចៀម**

១.៥.១. ចៀមគ្រប់ប្រភេទ ៖ ចាប់ពី១.០០០(មួយពាន់)ក្បាល ដល់តិចជាង៥.០០០(ប្រាំពាន់)ក្បាល

**១.៦. ស្វា**

១.៦.១. ស្វាគ្រប់ប្រភេទ ៖ ចាប់ពី១.០០០(មួយពាន់)ក្បាល  ដល់តិចជាង៥.០០០(ប្រាំពាន់)ក្បាល

**១.៧. ទន្សាយ**

១.៦.១. ទន្សាយគ្រប់ប្រភេទ ៖ ចាប់ពី១.០០០(មួយពាន់)ក្បាល  ដល់តិចជាង៥.០០០(ប្រាំពាន់)ក្បាល

**១.៨. សត្វស្លាប**

១.៨.១. មាន់យកស៊ុត ៖ ចាប់ពី២០.០០០(ពីរម៉ឺន)ក្បាល ដល់តិចជាង៥០.០០០(ប្រាំម៉ឺន)ក្បាល

១.៨.២. មាន់យកសាច់ ៖ ចាប់ពី៣០.០០០(បីម៉ឺន)ក្បាល ដល់តិចជាង៥០.០០០(ប្រាំម៉ឺន)ក្បាល

១.៨.៣. មាន់ពូជ ៖ មេ បា ចាប់ពី៥.០០០(ប្រាំពាន់)ក្បាល ដល់តិចជាង២០.០០០(ពីរម៉ឺន)ក្បាល

១.៨.៤. ទា ៖ ចាប់ពី២០.០០០(ពីរម៉ឺន)ក្បាល ដល់តិចជាង៥០.០០០(ប្រាំម៉ឺន)ក្បាល

១.៨.៥. ក្រួច ៖ ចាប់ពី៥០.០០០(ប្រាំម៉ឺន)ក្បាល ដល់តិចជាង១០០.០០០(ដប់ម៉ឺន)ក្បាល

**១.៩. ឃ្មុំ**

១.៩.១. ឃ្មុំគ្រប់ប្រភេទ ៖ ចាប់ពី៥០០(ប្រាំរយ)សំបុក ដល់តិចជាង១.០០០(មួយពាន់)សំបុក

**ខ.២. លក្ខខណ្ឌបច្ចេកទេស**

**២.១ ទីកន្លែង ឬកសិដ្ឋានចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វ**

- មិនត្រូវនៅជិតប្រភពទឹកប្រើប្រាស់ជាសាធារណៈ កន្លែងងាយរងគ្រោះដោយទឹកជំនន់ កន្លែងដែលលិចទឹក
- មានរបងព័ទ្ធជុំវិញកន្លែងចិញ្ចឹម
- មិនត្រូវស្ថិតនៅជិតសាលារៀន ទីប្រជុំជន ទីកន្លែងសាសនាផ្សេងៗ មន្ទីរពេទ្យ ផ្សារ សត្តឃាតដ្ឋាន ឬកន្លែងពិឃាតសត្វ
- អនុវត្តតាមគំរូប្លង់បច្ចេកទេស
- ដីកន្លែងចិញ្ចឹមសត្វមានប្លង់កម្មសិទ្ធិ
- មានកន្លែងស្តុកចំណី
- កន្លែងចិញ្ចឹមមានប្រព័ន្ធខ្យល់ចេញ ចូលបានល្អ។

**២.២ ចំណី និងទឹក**

- ផ្តល់ចំណីមានគុណភាពល្អ មានអនាម័យ និងមានសុវត្ថិភាពតាមបទដ្ឋានបច្ចេកទេសកំណត់ដោយបទប្បញ្ញត្តិនៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ និងគោលការណ៍ណែនាំរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- ហាមប្រើបសុឱសថ ឬចំណីសត្វដែលមានសារធាតុហាមឃាត់ សារធាតុគ្រោះថ្នាក់ សារធាតុជំរុញការលូតលាស់ខុសប្រក្រតី ឬប្រើផលិតផលសារពាង្គកាយរសកែច្នៃសេនេទិកហាមឃាត់ ដែលបង្កគ្រោះថ្នាក់ដល់សុខភាពសត្វ និងមនុស្ស
- ផ្តល់ទឹកស្អាត មានអនាម័យ និងគុណភាពតាមបទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធជាធរមាន និងគោលការណ៍ណែនាំរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- កត់ត្រាការប្រើប្រាស់ចំណី ទឹក និងបសុឱសថ។

**២.៣ ការគ្រប់គ្រងកសិដ្ឋាន**

- មានរចនាសម្ព័ន្ធចាត់តាំងរបស់កន្លែងចិញ្ចឹមសត្វ និងបញ្ជីបុគ្គលិក
- មានបុគ្គលិកបច្ចេកទេសទទួលខុសត្រូវម្នាក់ដែលមានសញ្ញាបត្រវិទ្យាសាស្ត្រសត្វកម្រិតបរិញ្ញាបត្រឡើងទៅ និងម្នាក់ទៀតមានសញ្ញាបត្រវេជ្ជសាស្ត្រសត្វកម្រិតបរិញ្ញាបត្រឡើងទៅ
- ប្រព័ន្ធគ្រប់គ្រងកន្លែងចិញ្ចឹមសត្វត្រូវបានកត់ត្រា និងអាចត្រួតពិនិត្យបាន
- កម្មករត្រូវមានសុខភាពល្អ
- កន្លែងចិញ្ចឹមមានអនាម័យស្របតាមបទដ្ឋានកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- មានកន្លែងប្រព្រឹត្តកម្មស្តុកកាកសំណល់ ឬឡជីវឧស្ម័ន។

## គ-ខ្នាតធំ

### គ.១. ប្រភេទសត្វ និងចំនួនសត្វ

**១.១. គោ ក្របី**

១.១.១. គោ ក្របីយកសាច់ ៖ ចាប់ពី១.០០០(មួយពាន់)ក្បាល ឡើងទៅ

១.១.២. គោ ក្របីយកទឹកដោះ ៖ មេចាប់៣០០(បីរយ)ក្បាល ឡើងទៅ

**១.២. សេះ**

១.២.១ សេះគ្រប់ប្រភេទ ៖ ចាប់ពី៥០០(ប្រាំរយ)ក្បាល ឡើងទៅ

**១.៣. ជ្រូក**

១.៣.១. ជ្រូកយកសាច់ ៖ ចាប់ពី៥.០០០(ប្រាំពាន់)ក្បាល ឡើងទៅ

១.៣.២. ជ្រូកពូជ ៖ មេ បា ចាប់ពី៥០០(ប្រាំរយ)ក្បាល ឡើងទៅ

**១.៤. ពពែ**

១.៤.១. ពពែគ្រប់ប្រភេទ ៖ ចាប់ពី៥.០០០(ប្រាំពាន់)ក្បាល ឡើងទៅ

**១.៥. ចៀម**

១.៥.១. ចៀមគ្រប់ប្រភេទ ៖ ចាប់ពី៥.០០០(ប្រាំពាន់)ក្បាល ឡើងទៅ

**១.៦. ស្វា**

១.៦.១. ស្វាគ្រប់ប្រភេទ ៖ ចាប់ពី៥.០០០(ប្រាំពាន់)ក្បាល ឡើងទៅ

**១.៧. ទន្សាយ**

១.៦.១. ទន្សាយគ្រប់ប្រភេទ ៖ ចាប់ពី៥.០០០(ប្រាំពាន់)ក្បាល ឡើងទៅ

**១.៨. សត្វស្លាប**

១.៨.១. មាន់យកស៊ុត ៖ ចាប់ពី៥០.០០០(ប្រាំម៉ឺន)ក្បាល ឡើងទៅ

១.៨.២. មាន់យកសាច់ ៖ ចាប់ពី៥០.០០០(ប្រាំម៉ឺន)ក្បាល ឡើងទៅ

១.៨.៣. មាន់ពូជ ៖ មេ បា ចាប់ពី២០.០០០(ពីរម៉ឺន)ក្បាល ឡើងទៅ

១.៨.៤. ទា ៖ ចាប់ពី៥០.០០០(ប្រាំម៉ឺន)ក្បាល ឡើងទៅ

១.៨.៥. ក្រួច ៖ ចាប់ពី១០០.០០០(ដប់ម៉ឺន)ក្បាល ឡើងទៅ

**១.៩. ឃ្មុំ**

១.៩.១. ឃ្មុំគ្រប់ប្រភេទ ៖ ចាប់ពី១.០០០(មួយពាន់)សំបុក ឡើងទៅ

## គ.២. លក្ខខណ្ឌបច្ចេកទេស

### ២.១ ទីកន្លែង ឬកសិដ្ឋានចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វ

- មិនត្រូវនៅជិតប្រភពទឹកប្រើប្រាស់ជាសាធារណៈ កន្លែងងាយរងគ្រោះដោយទឹកជំនន់ កន្លែងដែលលិចទឹក
- មានរបងព័ទ្ធជុំវិញកន្លែងចិញ្ចឹម
- មិនត្រូវស្ថិតនៅជិតសាលារៀន ទីប្រជុំជន ទីកន្លែងសាសនាផ្សេងៗ មន្ទីរពេទ្យ ផ្សារ សត្តឃាតដ្ឋាន ឬកន្លែងពិឃាតសត្វ
- អនុវត្តតាមគំរូប្លង់បច្ចេកទេស
- ដីកន្លែងចិញ្ចឹមសត្វមានប្លង់កម្មសិទ្ធិ
- មានកន្លែងស្តុកចំណី
- កន្លែងចិញ្ចឹមមានប្រព័ន្ធខ្យល់ចេញ ចូលបានល្អ។

### ២.២ ចំណី និងទឹក

- ផ្តល់ចំណីមានគុណភាពល្អ មានអនាម័យ និងមានសុវត្ថិភាពតាមបទដ្ឋានកំណត់ដោយច្បាប់ និងលិខិតបទបដ្ឋានរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- ហាមប្រើបសុឱសថ ឬចំណីសត្វដែលមានសារធាតុហាមឃាត់ សារធាតុគ្រោះថ្នាក់ សារធាតុជំរុញការលូតលាស់ខុសប្រក្រតី ឬប្រើផលិតផលសារពាង្គកាយរសកែច្នៃសេនេទិកហាមឃាត់ ដែលបង្កគ្រោះថ្នាក់ដល់សុខភាពសត្វ និងមនុស្ស
- ផ្តល់ទឹកស្អាត មានអនាម័យ និងគុណភាពតាមបទដ្ឋានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- កត់ត្រាការប្រើប្រាស់ចំណី ទឹក និងបសុឱសថ។

### ២.៣ ការគ្រប់គ្រងកសិដ្ឋាន

- មានរចនាសម្ព័ន្ធចាត់តាំងរបស់កន្លែងចិញ្ចឹមសត្វ និងបញ្ជីបុគ្គលិក
- មានបុគ្គលិកបច្ចេកទេសទទួលខុសត្រូវម្នាក់ដែលមានសញ្ញាបត្រវិទ្យាសាស្ត្រសត្វកម្រិតបរិញ្ញាបត្រឡើងទៅ និងម្នាក់ទៀតមានសញ្ញាបត្រវេជ្ជសាស្ត្រសត្វកម្រិតបរិញ្ញាបត្រឡើងទៅ
- ប្រព័ន្ធគ្រប់គ្រងកន្លែងចិញ្ចឹមសត្វត្រូវបានកត់ត្រា និងអាចត្រួតពិនិត្យបាន
- បុគ្គលិក និងកម្មករត្រូវមានសុខភាពល្អ
- កម្មករត្រូវបានបណ្តុះបណ្តាលសម្រាប់ការងារដែលទទួលខុសត្រូវ
- កម្មករត្រូវមានសម្លៀកបំពាក់ការពារ និងស្បែកជើងឱ្យបានសមស្រប
- កន្លែងចិញ្ចឹមមានអនាម័យស្របតាមបទដ្ឋានកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- ប្រើប្រាស់សារធាតុគីមី និងថ្នាំសម្លាប់មេរោគដែលត្រូវបានអនុញ្ញាតដោយច្បាប់ និងតាមបទដ្ឋានរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- មានកម្មវិធីធ្វើអនាម័យ និងបាញ់ថ្នាំសម្លាប់មេរោគ

- សំរាម សំណល់រឹង (រួមទាំងកាកសំណល់ជីវសាស្ត្រ) និងសំណល់រាវ ត្រូវបានគ្រប់គ្រង និងបំផ្លាញចោល ស្របតាមបទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធជាធរមាន និងគោលការណ៍ណែនាំរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- ប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត សត្វចង្រៃ អនុលោមតាមបទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធជាធរមាន និងគោលការណ៍ណែនាំរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងត្រូវបានកត់ត្រាដែលអាចតាមដានត្រួតពិនិត្យបាន
- សម្លេង ក្លិនចេញពីកន្លែងចិញ្ចឹមសត្វស្របតាមបទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធជាធរមាន និងគោលការណ៍ណែនាំរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- មានកន្លែងប្រព្រឹត្តកម្មស្តុកកាកសំណល់ ឬឡជីវឧស្ម័ន។

**២.៤ ការគ្រប់គ្រងសុខភាពសត្វ**

- មានសៀវភៅកត់ត្រាការប្រើប្រាស់បសុឱសថ និងវ៉ាក់សាំង
- មានរបាយការណ៍ស្តីពីស្ថានភាពនៃការប្រើប្រាស់ចំណីសត្វ
- មានផែនការ និងវិធីសាស្ត្រដោះស្រាយពេលមានផ្ទុះជំងឺឆ្លងរាតត្បាត។

**២.៥ អត្តសញ្ញាណកម្មសត្វ**

- សត្វត្រូវមានអត្តសញ្ញាណកម្ម។

**២.៦ សុខុមាលភាពសត្វ**

- អនុវត្តតាមបទដ្ឋានបច្ចេកទេសកំណត់ដោយបទប្បញ្ញត្តិនៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ និងគោលការណ៍ណែនាំរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

**២.៧ ការរក្សាទុកដាក់កំណត់ត្រា**

- ត្រូវរក្សាកំណត់ត្រាស្តីពីការគ្រប់គ្រងកសិដ្ឋាន ស្ថិតិសត្វ ផលិតកម្មប្រចាំខែ ឆ្នាំ សុខភាពសត្វ ការបន្តពូជ អត្តសញ្ញាណកម្មសត្វ។ល។ ដើម្បីសមត្ថកិច្ចជំនាញអាចត្រួតពិនិត្យ តាមដាន និងវាយតម្លៃបាន។

ឧបសម្ព័ន្ធទី២ នៃប្រកាសលេខ.........................ប្រក.កសក ចុះថ្ងៃទី.............ខែ................ឆ្នាំ២០១....

ស្ដីពី "**ចំណាត់ថ្នាក់ខ្នាត បទដ្ឋានបច្ចេកទេស និងនីតិវិធី**
**សម្រាប់ការផ្ដល់លិខិតអនុញ្ញាតការចិញ្ចឹមសត្វនិងការបង្កាត់ពូជសត្វ**"

## សំណុំបែបបទ
## សម្រាប់ការស្នើសុំលិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ
## និងគំរូលិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ

២.១- គំរូពាក្យស្នើសុំលិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ ខ្នាតតូច
២.២- គំរូពាក្យស្នើសុំលិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ ខ្នាតមធ្យម និងខ្នាតធំ
២.៣- គំរូប្រវត្តិរូបសង្ខេប (សម្រាប់អ្នកស្នើសុំបង្កើតកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ)
២.៤- គំរូកិច្ចសន្យាស្ដីពីការបង្កើតកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ
២.៥- គំរូគំនូសប្លង់បច្ចេកទេសសម្រាប់ការបង្កើតកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ
២.៦- គំរូបទបញ្ជាផ្ទៃក្នុងសម្រាប់កសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ
២.៧- គំរូលិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ ខ្នាតតូច
២.៨- គំរូលិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ ខ្នាតមធ្យម និងខ្នាតធំ
២.៩- គំរូកិច្ចសន្យាស្ដីពីការគ្រប់គ្រងបច្ចេកទេសកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គំរូទី២.១

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................. ភេទ............. អាយុ.........ឆ្នាំ ជនជាតិ............ សញ្ជាតិ.............
មុខរបរ/តួនាទី..........................................................................................លេខទូរស័ព្ទ....................................
មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.......................ផ្លូវ.......................ក្រុមទី.............ភូមិ/មណ្ឌល..............................
ឃុំ/សង្កាត់...............................ក្រុង/ស្រុក/ខណ្ឌ....................................រាជធានី/ខេត្ត..............................។

**សូមគោរពជូន**
**លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី/ខេត្ត**..................

**តាមរយៈ** ៖ លោក/លោកស្រីប្រធានការិយាល័យផលិតកម្ម និងបសុព្យាបាល រាជធានី/ខេត្ត..........................
**កម្មវត្ថុ** ៖ សំណើសុំបង្កើតកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ ខ្នាតតូច
**យោង** ៖ -ព្រះរាជក្រមលេខ នស/រកម/០១១៦/០០៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ
-ប្រកាសលេខ................ប្រក.កសក ចុះថ្ងៃទី..........ខែ..........ឆ្នាំ២០....... ស្តីពីចំណាត់ថ្នាក់ខ្នាតបទដ្ឋានបច្ចេកទេស និងនីតិវិធីសម្រាប់ការផ្តល់លិខិតអនុញ្ញាតការចិញ្ចឹមសត្វនិងការបង្កាត់ពូជសត្វ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកប្រធានមន្ទីរ** មេត្តាជ្រាបថា៖ ខ្ញុំបាទ/នាងខ្ញុំ មានបំណងបង្កើតកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ ☐គោ-ក្របីយកសាច់, ☐គោ-ក្របីយកទឹកដោះ, ☐សេះ, ☐ជ្រូកសាច់, ☐ជ្រូកពូជ, ☐ពពែ, ☐ចៀម, ☐ស្វា, ☐ទន្សាយ, ☐មាន់យកស៊ុត, ☐មាន់យកសាច់, ☐មាន់ពូជ, ☐ទា, ☐ក្រួច, ☐ឃ្មុំ, ☐សត្វផ្សេងៗ........................................................................
ឈ្មោះកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ..............................................................................................
មានទីតាំងស្ថិតនៅ ៖ ចំណុច....................................ផ្លូវ..................................ភូមិ/មណ្ឌល..............................
ឃុំ/សង្កាត់...................................ក្រុង/ស្រុក/ខណ្ឌ....................................រាជធានី/ខេត្ត...........................។

**<u>សូមជូនភ្ជាប់ជាមួយនូវ</u>** ៖
-ប្រវត្តិរូបសង្ខេបមានបិទរូបថត(៤x៦) ដោយមានបញ្ជាក់ទទួលស្គាល់ពីមេឃុំ/ចៅសង្កាត់............................០២ច្បាប់
-អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ (ថតចម្លង)....................................................០២ច្បាប់
-កិច្ចសន្យាស្តីពីការបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ....................................................០២ច្បាប់
-លិខិតបញ្ជាក់ទីតាំងដោយមានចុះទិដ្ឋាការពីអាជ្ញាធរដែនដី..............................................................០២ច្បាប់
-គំនូសប្លង់បច្ចេកទេសកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ..........................................................០២ច្បាប់
-ផែនការផលិតកម្មសត្វ.................................................................................................................០២ច្បាប់

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកប្រធានមន្ទីរ** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

ថ្ងៃ.............................ខែ.......................ឆ្នាំ...............ព.ស.២៥...
ធ្វើនៅ...........................ថ្ងៃទី.........ខែ...........ឆ្នាំ២០....

**ស្នាមមេដៃស្តាំឬហត្ថលេខា**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គំរូទី២.២

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................... ភេទ............. អាយុ.........ឆ្នាំ ជនជាតិ............ សញ្ជាតិ............
មុខរបរ/តួនាទី................................................................................លេខទូរស័ព្ទ...............................
មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.......................ផ្លូវ......................ក្រុមទី.............ភូមិ/មណ្ឌល..........................
ឃុំ/សង្កាត់.................................ក្រុង/ស្រុក/ខណ្ឌ..................................រាជធានី/ខេត្ត..............................។

**សូមគោរពជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**

**អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ**

**តាមរយៈ** ៖ -លោក/លោកស្រីប្រធានការិយាល័យផលិតកម្ម និងបសុព្យាបាល រាជធានី/ខេត្ត.........................
-លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី/ខេត្ត...........................................

**កម្មវត្ថុ** ៖ សំណើសុំបង្កើតកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ ☐ខ្នាតមធ្យម, ☐ខ្នាតធំ

**យោង** ៖ -ព្រះរាជក្រមលេខ នស/រកម/០១១៦/០០៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ
-ប្រកាសលេខ................ប្រក.កសក ចុះថ្ងៃទី..........ខែ..........ឆ្នាំ២០....... ស្តីពីចំណាត់ថ្នាក់ខ្នាតបទដ្ឋានបច្ចេកទេស និងនីតិវិធីសម្រាប់ការផ្តល់លិខិតអនុញ្ញាតការចិញ្ចឹមសត្វនិងការបង្កាត់ពូជសត្វ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រតិភូ** មេត្តាជ្រាបថា ៖ ខ្ញុំបាទ/នាងខ្ញុំ មានបំណងបង្កើតកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ ☐គោ-ក្របីយកសាច់, ☐គោ-ក្របី យកទឹកដោះ, ☐សេះ, ☐ជ្រូកសាច់, ☐ជ្រូកពូជ, ☐ពពែ, ☐ចៀម, ☐ស្វា, ☐ទន្សាយ, ☐មាន់យកស៊ុត, ☐មាន់យកសាច់, ☐មាន់ពូជ, ☐ទា, ☐ក្រួច, ☐ឃ្មុំ, ☐សត្វផ្សេងៗ.......................................................................
ឈ្មោះកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ..............................................................................................
មានទីតាំងស្ថិតនៅ ៖ ចំណុច...................................ផ្លូវ.............................ភូមិ/មណ្ឌល.................................
ឃុំ/សង្កាត់....................................ក្រុង/ស្រុក/ខណ្ឌ...................................រាជធានី/ខេត្ត.........................។

**<u>សូមជូនភ្ជាប់ជាមួយនូវ</u>** ៖
-ប្រវត្តិរូបសង្ខេបមានបិទរូបថត(៤x៦) ដោយមានបញ្ជាក់ទទួលស្គាល់ពីមេឃុំ/ចៅសង្កាត់............................០២ច្បាប់
-អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកស្នើសុំ (ថតចម្លង)..................................................០២ច្បាប់
-កិច្ចសន្យាស្តីពីការបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ.....................................................០២ច្បាប់
-លិខិតបញ្ជាក់ទីតាំងដោយមានចុះទិដ្ឋាការពីអាជ្ញាធរដែនដី..............................................................០២ច្បាប់
-លិខិតបញ្ជាក់ជាបុគ្គលិកបច្ចេកទេសទទួលខុសត្រូវកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វជំនាញវិទ្យាសាស្ត្រសត្វ ១រូប និងជំនាញវេជ្ជសាស្ត្រសត្វ ១រូប..................................................................................០២ច្បាប់
-គំនូសប្លង់បច្ចេកទេសកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ...........................................................០២ច្បាប់
-ផែនការផលិតកម្មសត្វ..............................................................................................................០២ច្បាប់

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រតិភូ** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

ថ្ងៃ..............................ខែ............ឆ្នាំ...........ព.ស.២៥...
ធ្វើនៅ............................ថ្ងៃទី.........ខែ............ឆ្នាំ២០....

**ស្នាមមេដៃស្តាំឬម្រាមដៃ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គំរូទី២.៣

រូបថត
៤x៦

# ប្រវត្តិរូបសង្ខេប

នាមត្រកូល និង នាមខ្លួន ៖.............................................អក្សរឡាតាំង...........................................

ភេទ.................ជនជាតិ......................សញ្ជាតិ................ថ្ងៃខែឆ្នាំកំណើត...........................................

ទីកន្លែងកំណើត ៖..........................................................................................................................

អត្តសញ្ញាណប័ណ្ណលេខ/លិខិតឆ្លងដែនលេខ (ថតចម្លង).................................................................

អាសយដ្ឋានស្នាក់នៅបច្ចុប្បន្ន ៖ ផ្ទះលេខ.........................ផ្លូវ.........................ភូមិ...............................

ឃុំ/សង្កាត់..............................ក្រុង/ស្រុក/ខណ្ឌ........................................រាជធានី/ខេត្ត.......................

ទូរស័ព្ទលេខ ៖..............................................................................................................................

កម្រិតវប្បធម៌ ៖.............................................................................................................................

បច្ចេកទេសជំនាញ ៖.......................................................................................................................

មុខរបរបច្ចុប្បន្ន ៖..........................................................................................................................

ឈ្មោះប្រពន្ធ ឬ ប្តី ៖.........................................ថ្ងៃខែឆ្នាំកំណើត..................................................

មុខរបរបច្ចុប្បន្ន ៖..........................................................................................................................

ចំនួនកូន ៖.....................នាក់ ភេទ ស្រី...............នាក់ និង ប្រុស...................នាក់ ។

ថ្ងៃ..............................ខែ............ឆ្នាំ..........ព.ស ២៥...
ធ្វើនៅ...........................ថ្ងៃទី.........ខែ...........ឆ្នាំ២០...
**ស្នាមមេដៃស្តាំឬម្រាមដៃ**

លេខ.............................
បានឃើញ និងបញ្ជាក់ថា ៖

ឈ្មោះ....................................នេះពិតជា.............................
និងពិតជាកំពុងស្នាក់នៅបច្ចុប្បន្ន ផ្ទះលេខ.................ផ្លូវ..............
ភូមិ/មណ្ឌល..............................ក្រុង/ស្រុក/ខណ្ឌ.....................
រាជធានី/ខេត្ត.........................................នេះពិតប្រាកដមែន។
ថ្ងៃ.............................ខែ............ឆ្នាំ..........ព.ស ២៥...
ធ្វើនៅ.............................ថ្ងៃទី.........ខែ...........ឆ្នាំ២០...
ហត្ថលេខា និង ត្រា
**មេឃុំ/ចៅសង្កាត់**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គំរូទី២.៤

# កិច្ចសន្យា
# ស្តីពី
# ការបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................. ភេទ.............. អាយុ.............ឆ្នាំ ជនជាតិ.............. សញ្ជាតិ.............
មុខរបរ/តួនាទី.................................................................................................................................
មានទីលំនៅបច្ចុប្បន្នផ្ទះលេខ...........................ផ្លូវ.........................ក្រុមទី...............ភូមិ/មណ្ឌល...........................
ឃុំ/សង្កាត់...................................ក្រុង/ស្រុក/ខណ្ឌ..................................រាជធានី/ខេត្ត..............................។

បង្កើតកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ ៖ ☐ខ្នាតតូច, ☐ខ្នាតមធ្យម, ☐ខ្នាតធំ
ឈ្មោះកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ.............................................................................................
មានទីតាំងស្ថិតនៅ ៖ ចំណុច.............................. ភូមិ/មណ្ឌល........................ ឃុំ/សង្កាត់...........................
ក្រុង/ស្រុក/ខណ្ឌ.................................. រាជធានី/ខេត្ត..............................។

សូមសន្យាចំពោះ ☐អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ, ☐មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថា ខ្ញុំបាទ/នាង ខ្ញុំយល់ព្រម ៖

- គោរពតាមច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ
- គោរពតាមប្រកាសលេខ....................ប្រក.កសក ចុះថ្ងៃទី.........ខែ.........ឆ្នាំ........ ស្តីពី "ចំណាត់ថ្នាក់ខ្នាត បទដ្ឋានបច្ចេកទេស និងនីតិវិធីសម្រាប់ការផ្តល់លិខិតអនុញ្ញាតការចិញ្ចឹមសត្វនិងការបង្កាត់ពូជសត្វ"
- គោរពតាមបទដ្ឋានបច្ចេកទេសចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ និងអនុវត្តតាមវិធានការបសុព្យាបាល
- រាយការណ៍ពីស្ថិតិសត្វចិញ្ចឹមនៅរៀងរាល់៣(បី)ខែម្តង
- មិនទិញ ឬលួចនាំចូលសត្វខុសច្បាប់ពីប្រទេសជិតខាងដាក់ក្នុងកសិដ្ឋានចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វ
- រាល់ការដឹកជញ្ជូនសត្វធានាថាមានឯកសារគ្រប់គ្រាន់ និងស្ថិតក្នុងសុពលភាព
- បង្កលក្ខណៈងាយស្រួលក្នុងការត្រួតពិនិត្យដល់សមត្ថកិច្ចត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ
- ឧបករណ៍ចិញ្ចឹមសត្វ និងមធ្យោបាយដឹកជញ្ជូនសត្វ ធានាគុណភាព សុវត្ថិភាព និងអនាម័យ
- មិនលក់សិទ្ធិ ផ្ទេរសិទ្ធិ ឬផ្តល់សិទ្ធិឱ្យក្រុមហ៊ុន ឬបុគ្គលដទៃក្រៅពីឈ្មោះដែលបានអនុញ្ញាត
- មិនប្រើប្រាស់កសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វធ្វើជាមូលដ្ឋាននៃសកម្មភាពផ្សេងៗ ដែលផ្ទុយពីច្បាប់អនុញ្ញាតឡើយ។

ក្នុងករណីខ្ញុំបាទ/នាងខ្ញុំ មិនបានគោរព និងអនុវត្តផ្ទុយពីខ្លឹមសារដែលបានសន្យាខាងលើនេះ ខ្ញុំបាទ/នាងខ្ញុំសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ជាធរមាន។

ថ្ងៃ............................ខែ.............ឆ្នាំ............ព.ស ២៥....
ធ្វើនៅ..........................ថ្ងៃទី..............ខែ..........ឆ្នាំ២០.....

**ស្នាមមេដៃស្តាំឬម្រាមដៃ**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គំរូទី២.៥

### គំនូសប្លង់បច្ចេកទេសសម្រាប់ការបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គំរូទី២.៦

# បទបញ្ជាផ្ទៃក្នុង
# សម្រាប់កសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ

ដើម្បីធានាបាននូវអនាម័យ និងជីវសុវត្ថិភាពត្រឹមត្រូវនៅក្នុងកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ រក្សាបានសុវត្ថិភាព សុខភាពសត្វ សុខុមាលភាពសត្វ និងសុខភាពសាធារណៈ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ សម្រេចកំណត់នូវបទបញ្ជាផ្ទៃក្នុងសម្រាប់កសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ ដូចខាងក្រោម ៖

**១-កន្លែងចិញ្ចឹមសត្វ និងកន្លែងបង្កាត់ពូជសត្វ**

- ត្រូវមានអនាម័យល្អ និងធ្វើការលាងសម្អាតសម្លាប់មេរោគតាមបច្ចេកទេសបសុព្យាបាល
- សម្ភារប្រើប្រាស់សម្រាប់ការចិញ្ចឹមសត្វ និងការបង្កាត់ពូជសត្វត្រូវមានអនាម័យល្អ
- អ្នកគ្មានភារកិច្ចហាមចេញ ចូលក្នុងកសិដ្ឋានចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វ
- ត្រូវផ្តល់ទឹក និងចំណីដល់សត្វឲ្យបានគ្រប់គ្រាន់ ទាំងបរិមាណ និងគុណភាព
- ហាមធ្វើទារុណកម្មសត្វ ដូចជាវាយដំ បញ្ច្រកទឹក បញ្ច្រកចំណី និងធ្វើទារុណកម្មសត្វតាមរូបភាពផ្សេងៗទៀត
- ត្រូវរក្សាសណ្តាប់ធ្នាប់ សន្តិសុខ និងរបៀបរៀបរយនៅក្នុងកសិដ្ឋានចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វ
- ត្រូវមានកំណត់ត្រាសកម្មភាពប្រចាំថ្ងៃនៅក្នុងកសិដ្ឋានចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វ។

**២-បុគ្គលិក កម្មករ និងអ្នកបំពេញការងារនៅក្នុងកសិដ្ឋានចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វ**

- បុគ្គលិក កម្មករ និងអ្នកបំពេញការងារក្នុងកសិដ្ឋានចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វត្រូវមានសុខភាពល្អ
- បុគ្គលិក កម្មករត្រូវមានអនាម័យ ហាមជក់បារី ក្នុងកន្លែងធ្វើការ។

**៣-សម្លៀកបំពាក់ សម្រាប់អ្នកបំពេញការងារនៅក្នុងកសិដ្ឋានចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វ**

- អាវដៃខ្លី ឬដៃវែងជីបចុងដៃ ក្រណាត់ពណ៌ផ្ទៃមេឃ
- ខោជើងវែង ក្រណាត់ពណ៌ផ្ទៃមេឃ
- គម្របក្បាល ក្រណាត់ពណ៌ផ្ទៃមេឃ
- ស្បែកជើងកវែង មិនជ្រាបទឹក ពណ៌ស
- អាវអៀមផ្លាស្ទិក ពណ៌ស
- ស្រោមដៃពណ៌ស។

ខ្ញុំបាទ/នាងខ្ញុំ សូមសន្យាចំពោះ ☐អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ, ☐មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថា ខ្ញុំបាទ/នាង ខ្ញុំយល់ព្រមទទួល និងអនុវត្តតាមបទបញ្ជាផ្ទៃក្នុងនេះ ស្របតាមគោលការណ៍ច្បាប់កំណត់។

ថ្ងៃ..............................ខែ..............ឆ្នាំ..........ពស..........

ធ្វើនៅ............................ថ្ងៃទី..........ខែ..............ឆ្នាំ២០....

ស្នាមមេដៃស្តាំឬម្រាមដៃ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គំរូទី២.៧

| រូបថត<br>៤ X ៦ |
|---|

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី/ខេត្ត..........**
លេខ..........................មក.កចស

# លិខិតអនុញ្ញាតបង្កើត
# កសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/០០៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីសុខភាពសត្វ និងផលិតកម្មសត្វ
- យោងប្រកាសលេខ.........................ប្រក.កសក ចុះថ្ងៃទី...............ខែ...............ឆ្នាំ២០...... របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និនេសាទ
- យោងលិខិតឯកភាពជាគោលការណ៍លេខ.................សជស ចុះថ្ងៃទី.........ខែ.........ឆ្នាំ២០... របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- យោងលិខិតស្នើសុំបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វរបស់...........................................ចុះថ្ងៃទី...........ខែ..............ឆ្នាំ២០......

បានអនុញ្ញាតឲ្យលោក-លោកស្រី..........................................ភេទ..............អាយុ...........ឆ្នាំ សញ្ជាតិ................មុខរបរបច្ចុប្បន្ន..........................
អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ................. ផ្លូវ.............. ភូមិ/មណ្ឌល................. ឃុំ/សង្កាត់.................. ក្រុង/ស្រុក/ខណ្ឌ................... រាជធានី-ខេត្ត.........
កាន់អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនលេខ............................................ ចេញដោយ.........................................................................
បង្កើតកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ **ខ្នាតតូច** ឈ្មោះកសិដ្ឋាន..............................................................................................
មានទីតាំងស្ថិតនៅ ភូមិ/មណ្ឌល......................... ឃុំ/សង្កាត់............................ ក្រុង/ស្រុក/ខណ្ឌ.............................. រាជធានី-ខេត្ត.........................
លិខិតអនុញ្ញាតនេះមានសុពលភាពរយៈពេល ៥(ប្រាំ)ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី...........ខែ...........ឆ្នាំ២០...... រហូតដល់ថ្ងៃទី...........ខែ...........ឆ្នាំ២០.........
សាមីជនដែលទទួលបានការអនុញ្ញាតឲ្យបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ ត្រូវគោរពនិងអនុវត្តឲ្យបានត្រឹមត្រូវតាមខ្លឹមសារដូចមានចែងក្នុងច្បាប់ស្ដីពីសុខភាពសត្វ និងផលិតកម្មសត្វ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ថ្ងៃ.........................ខែ............ឆ្នាំ...........ព.ស.២៥....
ធ្វើនៅ.........................ថ្ងៃទី..........ខែ............ឆ្នាំ២០...

**ប្រធានមន្ទីរ**

គំរូទី២.៨

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រូបថត
៤ x ៦

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
លេខ.........................សផស.កចស

# លិខិតអនុញ្ញាតបង្កើត
# កសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/០០៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ
- យោងប្រកាសលេខ........................ប្រក.កសក ចុះថ្ងៃទី..............ខែ..............ឆ្នាំ២០...... របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងលិខិតឯកភាពជាគោលការណ៍លេខ................................ចុះថ្ងៃទី..............ខែ..............ឆ្នាំ២០...... របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងលិខិតស្នើសុំបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វរបស់........................................................ចុះថ្ងៃទី..........ខែ.............ឆ្នាំ២០.....

បានអនុញ្ញាតឲ្យលោក-លោកស្រី..................................................ភេទ..............អាយុ............ឆ្នាំ សញ្ជាតិ...............មុខរបរបច្ចុប្បន្ន..........................
អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ.................ផ្លូវ..............ភូមិ/មណ្ឌល.................ឃុំ/សង្កាត់..................ក្រុង/ស្រុក/ខណ្ឌ...................រាជធានី/ខេត្ត.........
កាន់អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនលេខ...................................................ចេញដោយ..................................................................
បង្កើតកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ ខ្នាត.....................ឈ្មោះកសិដ្ឋាន.................................................................................
មានទីតាំងស្ថិតនៅ ភូមិ/មណ្ឌល........................ឃុំ/សង្កាត់...........................ក្រុង/ស្រុក/ខណ្ឌ.............................រាជធានី/ខេត្ត...........................
លិខិតអនុញ្ញាតនេះមានសុពលភាពរយៈពេល ៥(ប្រាំ)ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី..........ខែ..........ឆ្នាំ២០..... រហូតដល់ថ្ងៃទី..........ខែ..........ឆ្នាំ២០........
សាមីជនដែលទទួលបានការអនុញ្ញាតឲ្យបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វត្រូវគោរពនិងអនុវត្តឲ្យបានត្រឹមត្រូវតាមខ្លឹមសារដូចមានចែងក្នុងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ថ្ងៃ.........................ខែ............ឆ្នាំ...........ព.ស.២៥...
ធ្វើនៅ.........................ថ្ងៃទី..........ខែ............ឆ្នាំ២០...

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**
**អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គំរូទី២.៩

# កិច្ចសន្យា
## ស្តីពី
## ការគ្រប់គ្រងបច្ចេកទេសកសិដ្ឋានចិញ្ចឹមសត្វ និង/ឬបង្កាត់ពូជសត្វ
**មានទីតាំងស្ថិតនៅ**........................................................................................
**របស់**..........................................................................................................

យោងលិខិតលេខ...........................បុះថ្ងៃ.....................ខែ.............ឆ្នាំ...........សំរឹទ្ធិស័ក ព.ស............ ត្រូវនឹងថ្ងៃទី..........ខែ...........ឆ្នាំ........... របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានសម្រេចអនុញ្ញាតជាគោលការណ៍ឱ្យ.......................................................................... បង្កើតកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ ខ្នាត...................មានទីតាំងស្ថិតនៅភូមិ............................... ឃុំ/សង្កាត់.................................ក្រុង/ស្រុក/ខណ្ឌ............................រាជធានី/ខេត្ត.................................។

## កិច្ចសន្យានេះធ្វើឡើងរវាង

**នាយកដ្ឋានផលិតកម្មសត្វ នៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ ឬការិយាល័យផលិតកម្ម និងបសុពេទ្យាបាល នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** មានអាសយដ្ឋាននៅផ្លូវលេខ................. ភូមិ.................. ឃុំ/សង្កាត់.................ក្រុង/ស្រុក/ខណ្ឌ................ រាជធានី/ខេត្ត.............. តំណាងដោយ......................... *(ប្រធាននាយកដ្ឋានផលិតកម្មសត្វ ឬប្រធានការិយាល័យផលិតកម្ម និបសុព្យាបាល)* ទូរស័ព្ទលេខ........................ ហៅកាត់ថាភាគី "ក" ។

## ជាមួយនឹង

..............................................ជាម្ចាស់កសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ ខ្នាត.................... មានទីតាំងស្ថិតនៅភូមិ..................ឃុំ/សង្កាត់................ក្រុង/ស្រុក/ខណ្ឌ...............រាជធានី/ខេត្ត................... ទូរស័ព្ទលេខ................................ ហៅកាត់ថាភាគី "ខ" ។

ភាគីទាំងពីរបានឯកភាពគ្នាតាមប្រការទាំងឡាយនៃកិច្ចសន្យាដូចមានចែងខាងក្រោមនេះ ៖

### ប្រការ ១ ៖ កម្មវត្ថុនៃកិច្ចសន្យា

ភាគី "ក" យល់ព្រមឱ្យភាគី "ខ" ដំណើរការកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ ខ្នាត.................. មានទីតាំងស្ថិតនៅភូមិ............ឃុំ/សង្កាត់..............ក្រុង/ស្រុក/ខណ្ឌ...........រាជធានី/ខេត្ត.............។

### ប្រការ ២៖ អំពីថេរវេលា

២.១. កិច្ចសន្យានេះមានរយៈពេលប្រាំ(៥)ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី..........ខែ.........ឆ្នាំ..........រហូតដល់ថ្ងៃទី.........ខែ.........ឆ្នាំ..........លើកលែងតែមានការព្យួរ ឬដកហូតដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅមុនកាលបរិច្ឆេទផុតសុពលភាព។

២.២. ក្នុងរយៈពេល៦(ប្រាំមួយ)ខែ មុនកាលបរិច្ឆេទផុតសុពលភាព ភាគី "ខ" ត្រូវស្នើសុំបន្តសុពលភាពសារជាថ្មី។ ក្នុងករណីខកខានក្នុងការស្នើសុំជាថ្មី លិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វនេះនឹងត្រូវនិរាករណ៍ដោយស្វ័យប្រវត្តិនូវកាលបរិច្ឆេទផុតសុពលភាព។

**ប្រការ ៣ ៖ ការដឹកជញ្ជូនសត្វ និងផលិតផលរបស់កសិដ្ឋាន**

៣.១. ភាគី "ក" សម្របសម្រួលក្នុងការចេញលិខិតអនុញ្ញាតឱ្យភាគី "ខ" ដឹកជញ្ជូនសត្វ និងផលិតផលដែលកសិដ្ឋានផលិតបាន ដើម្បីចរាចរណ៍លក់ដូរ ឬកែច្នៃនៅក្នុងប្រទេស ឬនាំចេញទៅក្រៅប្រទេស ដោយអនុលោមតាមច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ និងលិខិតបទដ្ឋានជាធរមាន។

៣.២. សត្វ និងផលិតផលដែលកសិដ្ឋានផលិតបាន អាចដឹកជញ្ជូនបានត្រូវមានវិញ្ញាបនបត្របញ្ជាក់អនាម័យសត្វ និងផលិតផលសត្វ និងលិខិតបទដ្ឋានពាក់ព័ន្ធ។

**ប្រការ ៤ ៖ សិទ្ធិនិងភារកិច្ចរបស់ភាគី "ក"**

ភាគី "ក" មានសិទ្ធិ និងភារកិច្ចដូចខាងក្រោម ៖

៤.១. ជួយសម្របសម្រួលក្នុងការស្នើសុំលិខិតអនុញ្ញាតឱ្យភាគី "ខ" ដឹកជញ្ជូនបសុឱសថ វ៉ាក់សាំង ចំណី និងសម្ភារបម្រើឱ្យការចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ ក្រោយពេលទទួលបានគោលការណ៍អនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៤.២. តាមដាន និងពិនិត្យលើការអនុវត្តកិច្ចសន្យា និងផលប៉ះពាល់បណ្តាលពីផលិតកម្មសត្វ។

៤.៣. តាមដានការអនុវត្តដំណើរការសាងសង់កសិដ្ឋាន ការចិញ្ចឹមសត្វ ដោយផ្អែកតាមគំនូសប្លង់បច្ចេកទេស ឬគោលការណ៍ណែនាំស្តីពីការអនុវត្តការចិញ្ចឹមសត្វល្អ/GAHP។

៤.៤. ជួយសម្របសម្រួលឱ្យភាគី "ខ" ក្នុងការស្នើសុំចុះបញ្ជីកសិដ្ឋានចិញ្ចឹមសត្វ និងចេញវិញ្ញាបនបត្របញ្ជាក់ការអនុវត្តការចិញ្ចឹមសត្វល្អ/GAHP។

៤.៥. ត្រួតពិនិត្យ និងធ្វើការណែនាំបច្ចេកទេសគ្រប់គ្រងកសិដ្ឋាន ការប្រើប្រាស់បសុឱសថ និងចំណីសត្វ។

៤.៦. ធ្វើការអប់រំ និងណែនាំដល់ភាគី "ខ" អំពីប្រព័ន្ធជីវសុវត្ថិភាព និងការគ្រប់គ្រងកាកសំណល់។

៤.៧. តាមដានស្ថានភាពជំងឺសត្វ ចំណីសត្វ និងចុះយកវត្ថុវិភាគលើសត្វ ចំណីសត្វ និងបសុឱសថ។ រាល់ការចំណាយលើការពិនិត្យវត្ថុវិភាគជាបន្ទុករបស់ភាគី "ខ" ។

៤.៨. ជួយសម្របសម្រួលជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនានា រាល់សកម្មភាពរំលោភលើសិទ្ធិភាគី "ខ" ក្នុងក្របខណ្ឌនៃកិច្ចសន្យានេះ។

៤.៩. ធ្វើអធិការកិច្ច តាមដាន ស្រាវជ្រាវ និងចាត់វិធានការបច្ចេកទេសនានា ឬអនុវត្តវិធានបសុព្យាបាលក្នុងកសិដ្ឋានក្នុងករណីចាំបាច់។

**ប្រការ ៥ ៖ សិទ្ធិ និងភារកិច្ចរបស់ភាគី "ខ"**

ភាគី "ខ" ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម ៖

៥.១. ត្រូវមានបុគ្គលិកបច្ចេកទេសទទួលខុសត្រូវចំនួន ២នាក់ ដែលមានសញ្ញាបត្រកម្រិតបរិញ្ញាឡើងទៅ (ម្នាក់ជំនាញវិទ្យាសាស្ត្រសត្វ និងម្នាក់ទៀតជំនាញវេជ្ជសាស្ត្រសត្វ) សម្រាប់បម្រើការងារនៅក្នុងកសិដ្ឋានចិញ្ចឹមសត្វ និង/ឬបង្កាត់ពូជសត្វ *(សម្រាប់តែកសិដ្ឋានខ្នាតមធ្យម និងខ្នាតធំ)*។

៥.២. ត្រូវចុះបញ្ជីកសិដ្ឋានចិញ្ចឹមជ្រូកពូជ ចេញដោយភាគី "ក" ។

៥.៣. ត្រូវគោរពតាមលក្ខខណ្ឌបច្ចេកទេសក្នុងការសាងសង់កសិដ្ឋានចិញ្ចឹមសត្វ និង/ឬបង្កាត់ពូជសត្វស្របតាមគំនូសប្លង់បច្ចេកទេស ឬគោលការណ៍ណែនាំស្តីពីការអនុវត្តការចិញ្ចឹមសត្វល្អ/GAHP និងអាចស្នើសុំវិញ្ញាបនបត្របញ្ជាក់ការអនុវត្តការចិញ្ចឹមសត្វល្អ/GAHP ចេញដោយភាគី "ក"

៥.៤. ត្រូវគោរពតាមលក្ខខណ្ឌបច្ចេកទេសក្នុងការចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ ស្របតាមគោលការណ៍ណែនាំស្តីពីសុខុមាលភាពសត្វ និងនិរន្តរភាពបរិស្ថាន ឬគោលការណ៍ណែនាំ GAHP។

៥.៥. ត្រូវគោរពបទប្បញ្ញត្តិស្តីពីវិធានការការពារជំងឺឆ្លងសត្វ និងវិធានការអនាម័យសត្វឱ្យបានត្រឹមត្រូវ

៥.៦. ត្រូវមានសៀវភៅកត់ត្រាការប្រើប្រាស់បសុឱសថ វ៉ាក់សាំង ការប្រើប្រាស់ចំណីសត្វ និងថែរក្សាកំណត់ត្រាស្តីពីការគ្រប់គ្រងកសិដ្ឋាន ស្ថិតិសត្វ ផលិតកម្មប្រចាំខែ ឆ្នាំ សុខភាពសត្វ ការបន្តពូជ អត្តសញ្ញាណកម្មសត្វ។ល។ ដើម្បីសមត្ថកិច្ចជំនាញអាចត្រួតពិនិត្យ តាមដាន និងវាយតម្លៃបាន។

៥.៧. រាល់ការនាំចូលនូវបសុឱសថ វ៉ាក់សាំង ចំណី សម្ភារបម្រើឱ្យការចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ ត្រូវសុំការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៥.៨. ត្រូវមានការិយាល័យបម្រើការងារ កន្លែងស្នាក់នៅរបស់បុគ្គលិក កម្មករ ប្រចាំការនៅកសិដ្ឋាន។

៥.៩. មិនត្រូវប្រើប្រាស់បសុឱសថ ឬចំណីសត្វ ដែលមានសារជាតុហាមឃាត់ សារជាតុគ្រោះថ្នាក់ សារជាតុជំរុញការលូតលាស់របស់សត្វខុសប្រក្រតី ប្រើប្រាស់អង់ទីប៊ីយូទិកលើសការកំណត់ ឬប្រើផលិតផលសារពាង្គកាយរស់កែច្នៃសេនេទិកហាមឃាត់ ដែលបង្កគ្រោះថ្នាក់ដល់សុខភាពសត្វ និងមនុស្ស។

៥.១០. ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងករណីដែលផលិតផលរបស់កសិដ្ឋានបានបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ ដោយសារសេនេទិក ផលិតផលគ្មានអនាម័យ ឬសារពាង្គកាយរស់កែច្នៃ ជាតិវិទ្យុសកម្ម ជាតិគីមី សារជាតុជីវគីមី(អ័រម៉ូន) ឬបសុឱសថដែលច្បាប់ហាមឃាត់។

៥.១១. មានសិទ្ធិជួលអ្នកឯកទេសខ្មែរក្នុងឬក្រៅប្រទេស និងកម្មករខ្មែរសម្រាប់បម្រើការងារតាមសេចក្តីត្រូវការចាំបាច់។ ក្នុងករណីមិនមានអ្នកឯកទេសខ្មែរ ភាគី **"ខ"** មានសិទ្ធិជួលអ្នកឯកទេសជាជនបរទេសបាន។

៥.១២. យកចិត្តទុកដាក់ចំពោះជីវភាព សុខភាពរបស់បុគ្គលិក កម្មករ និងមានកន្លែងស្នាក់នៅសមរម្យមានអនាម័យ មិនមានក្លិន និងសម្លេងប៉ះពាល់ដល់បរិស្ថាន។

៥.១៣. អនុញ្ញាតឱ្យអ្នកបច្ចេកទេស សិស្ស និស្សិតបានចុះសិក្សាស្រាវជ្រាវ ដកស្រង់បទពិសោធន៍ និងធ្វើកម្មសិក្សាលើការងារបច្ចេកទេស។

៥.១៤. អនុញ្ញាតឱ្យភាគី **"ក"** និងស្ថាប័នពាក់ព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីផលប៉ះពាល់បណ្តាលពីផលិតកម្មសត្វ និងត្រូវអនុវត្តតាមការណែនាំរបស់ភាគី **"ក"** ។

៥.១៥. ត្រូវមានបទបញ្ជាផ្ទៃក្នុងកសិដ្ឋានច្បាស់លាស់ ស្តីពីវិធីសាស្ត្រនៃការគ្រប់គ្រង និងផែនការដោះស្រាយ ឬបញ្ចៀសនៅពេលមានផ្ទុះជំងឺឆ្លងរាតត្បាត។

៥.១៦. ត្រូវមានប្រព័ន្ធជីវសុវត្ថិភាពរំងាប់មេរោគ និងការគ្រប់គ្រងកាកសំណល់ ដូចជាអាងប្រព្រឹត្តិកម្ម ឬសាងសង់ឡជីវឧស្ម័នក្នុងកសិដ្ឋាន។

៥.១៧. ត្រូវមានផែនការផលិតកម្មស្របតាមស្តង់ដារគុណភាព និងសុវត្ថិភាព ដោយអនុលោមតាមបទដ្ឋានបច្ចេកទេសជាធរមាន។

៥.១៨. ត្រូវផ្តល់របាយការណ៍ទៀងទាត់ជូនភាគី **"ក"** រៀងរាល់ប្រាំមួយខែម្តង រួមមានផែនការផលិតកម្ម ស្ថិតិសត្វចិញ្ចឹម និងស្ថានភាពជំងឺទូទៅក្នុងកសិកដ្ឋាន។

៥.១៩. ត្រូវរាយការណ៍ជូនភាគី **"ក"** ជាបន្ទាន់នៅពេលដែលសត្វក្នុងកសិដ្ឋានសង្ស័យ ឬផ្ទុះជំងឺឆ្លង។

៥.២០. មានសិទ្ធិចិញ្ចឹមសត្វ និង/ឬបង្កាត់ពូជសត្វ និងលក់ផលិតផលដែលកសិដ្ឋានផលិតបាននៅលើទីផ្សារក្នុងប្រទេស និងក្រៅប្រទេស។

៥.២១. ត្រូវគោរពច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ និងលិខិតបទដ្ឋានគតិយុត្តជាធរមានដែលពាក់ព័ន្ធនឹងគោលនយោបាយបង្កើត និងគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ។

៥.២២. បង្កភាពងាយស្រួលដល់មន្ត្រីជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល មានសមត្ថកិច្ចដើម្បីបំពេញភារកិច្ចត្រួតពិនិត្យអនាម័យ ការយកវត្ថុវិភាគ និងការអនុវត្តវិធានបសុព្យាបាល ឬការវាយតម្លៃតាមការចាំបាច់នៅក្នុងកសិដ្ឋាន។

៥.២៣. ត្រូវមានអត្តសញ្ញាណកម្មសម្គាល់សត្វក្នុងកសិដ្ឋាន *(សម្រាប់តែកសិដ្ឋានខ្នាតធំ)*។

៥.២៤. ត្រូវគោរពឱ្យបានត្រឹមត្រូវតាមប្រការទាំងឡាយដែលបានចែងក្នុងកិច្ចសន្យានេះ។

៥.២៥. ទទួលខុសត្រូវក្នុងការបង់កម្រៃសេវាសាធារណៈ និងកាតព្វកិច្ចពន្ធផ្សេងៗ ស្របតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៦ ៖ សិទ្ធិនៃការគ្រប់គ្រង**

៦.១. រាល់អចលនទ្រព្យ និងសមិទ្ធផលទាំងអស់ដែលស្ថិតនៅក្នុងកសិដ្ឋានហើយជាកម្មសិទ្ធិស្របច្បាប់របស់ភាគី "ខ" ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភាគី "ខ" ។

៦.២. រាល់ការផ្លាស់ប្តូរ ឬកែលម្អហេដ្ឋារចនាសម្ព័ន្ធជារូបវន្តដែលធ្វើឱ្យប៉ះពាល់បច្ចេកទេសនៃខ្សែច្រវាក់ផលិតកម្មសត្វ ភាគី "ខ" ត្រូវសុំការអនុញ្ញាតជាមុនពីភាគី "ក" ។

**ប្រការ ៧ ៖ ការព្រមព្រៀងទាំងស្រុង**

៧.១. កិច្ចសន្យានេះត្រូវបានបង្កើតឡើងដោយសុឆន្ទៈរវាងភាគីទាំងពីរដោយគ្មានការបង្ខិតបង្ខំពីភាគីណាមួយឡើយ។

៧.២. ភាគីទាំងពីរបានឯកភាពគ្នាថាខ្លឹមសារនៃកិច្ចសន្យានេះទោះក្នុងពាក្យនៃឃ្លាណាមួយ ប្រការណាមួយ ឬខ្លឹមសារទាំងមូលមិនអាចធ្វើការកែប្រែបានឡើយ លើកលែងតែមានការឯកភាពសរសេរជាលាយលក្ខណ៍អក្សរ ព្រមទាំងមានការចុះហត្ថលេខាទទួលស្គាល់ដោយភាគីទាំងពីរ។

**ប្រការ ៨ ៖ ការផ្ទេរសិទ្ធិឱ្យទៅតតិយជន(ភាគីទី ៣)**

៨.១. ភាគី "ខ" ធានាថានឹងមិនផ្ទេរសិទ្ធិ ឬបន្តសិទ្ធិទៅឱ្យបុគ្គលណាផ្សេងទៀតនូវកម្មវត្ថុនៃកិច្ចសន្យានេះទោះក្នុងរូបភាពណាមួយ ឬផ្នែកណាមួយក៏ដោយ ដោយមិនមានការឯកភាពពីភាគី "ក" ជាមុនបានឡើយ។

៨.២. ប្រសិនជាមានការយល់ព្រមក្នុងការប្រគល់សិទ្ធិទៅតតិយជន នោះភាគី "ក" មានភារកិច្ចក្នុងការចែងនូវលក្ខខណ្ឌ និងកាតព្វកិច្ចពាក់ព័ន្ធដល់ភាគីតតិយជន ដើម្បីអនុវត្តន៍កិច្ចសន្យានេះឱ្យមានប្រសិទ្ធភាព។

**ប្រការ ៩ ៖ វិវាទនិងការដោះស្រាយ**

៩.១. ក្នុងករណីមានវិវាទកើតឡើងក្នុងរយៈពេលអនុវត្តកិច្ចសន្យានេះ ភាគីទាំងពីរត្រូវសម្របសម្រួលគ្នាធ្វើការដោះស្រាយដោយឈរលើគោលការណ៍ផលប្រយោជន៍ សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនីមួយៗ ដែលមានចែងក្នុងកិច្ចសន្យានេះ។

៩.២. ក្នុងករណីភាគីទាំងពីរមិនអាចឯកភាពគ្នា ភាគីនីមួយៗត្រូវស្វែងរកអាជ្ញាកណ្តាលណាមួយ ដើម្បីធ្វើការសម្របសម្រួល ក្នុងករណីអាជ្ញាកណ្តាលមិនអាចធ្វើការសម្របសម្រួលបាន ភាគីនីមួយៗមានសិទ្ធិដាក់ពាក្យបណ្តឹងទៅតុលាការ ឬសមត្ថកិច្ចស្របតាមគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ១០ ៖ ការប្រាស្រ័យទាក់ទង**

ភាគីទាំងពីរបានឯកភាពគ្នាថា រាល់ទំនាក់ទំនងកន្លងមកមុនការបង្កើតកិច្ចសន្យានេះទោះជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ក្តីត្រូវចាត់ទុកជាមោឃៈទាំងអស់ លើកលែងតែសំណើទាំងឡាយណាដែលកើតក្រោយកិច្ចសន្យានេះហើយមានការចុះហត្ថលេខាទទួលស្គាល់ដោយភាគីទាំងពីរ។

**ប្រការ ១១ ៖ ការបញ្ចប់កិច្ចសន្យា**

១១.១. ភាគី "ខ" មានសិទ្ធិដកហូតចេញពីគម្រោងការងារទាំងមូល ឬផ្នែកណាមួយក្នុងលក្ខខណ្ឌមិនអាចគ្រប់គ្រងបាន និងត្រូវមានការឯកភាពពីភាគី "ក" ។

១១.២. ក្នុងករណីដែលភាគី "ខ" ដកខ្លួនដោយខ្លួនឯង ឬមិនអនុវត្តពេញលេញនូវលក្ខខណ្ឌណាមួយនៃកិច្ចសន្យានេះ ឬច្បាប់ និងលិខិតបទដ្ឋានទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា ភាគី "ក" មានសិទ្ធិបញ្ឈប់កិច្ចសន្យានេះដោយគ្មានលក្ខខណ្ឌ និងមិនសងការខាតបង់ឡើយ។

១១.៣. ក្នុងករណីដែលភាគី "ខ" មិនបានគោរពតាមកិច្ចសន្យានេះ ដោយមិនបានចាប់ផ្តើមសកម្មភាពក្នុងរយៈពេលមួយ(១)ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខា ភាគី "ក" មានសិទ្ធិបញ្ឈប់កិច្ចសន្យានេះដោយគ្មានលក្ខខណ្ឌ និងគ្មានការសងនូវការខាតបង់ឡើយ។

១១.៤. កិច្ចសន្យានេះត្រូវបញ្ចប់នៅពេលផុតអាជ្ញាយុកាលក្នុងករណីភាគី "ខ" ពុំបានស្នើសុំបន្ត។

**ប្រការ ១២ ៖ ករណីប្រធានស័ក្តិ**

ក្នុងព្រឹត្តិការណ៍ដែលភាគីទាំងពីរមិនអាចបំពេញករណីយកិច្ចរបស់ខ្លួនជាផ្នែក ឬទាំងស្រុងបានអនុលោមទៅតាមលក្ខខណ្ឌផ្សេងៗនៃកិច្ចសន្យា ដោយសារតែករណីប្រធានស័ក្តិនោះ ភាគី **"ខ"** ត្រូវប្រកាសប្រាប់ភាគី "ក" ដោយសរសេរជាលាយលក្ខណ៍អក្សរបញ្ជាក់ពីហេតុផលរបស់ខ្លួនហើយកាតព្វកិច្ចរបស់ភាគី **"ខ"** នឹងត្រូវផ្អាកការងារបណ្តោះអាសន្នក្នុងកំឡុងពេលដែលជាប់ពាក់ព័ន្ធនោះ ។

**ពាក្យប្រធានស័ក្តិរួមមាន** ៖ ភ្លើងឆេះ ទឹកជំនន់ ខ្យល់ព្យុះ សង្គ្រាមស៊ីវិល រញ្ជួយផែនដី ការចលាចលសកម្មភាពបះបោរ កុប្បកម្ម ជំងឺឆ្លងរាតត្បាតសត្វ ព្រមទាំងព្រឹត្តិការណ៍ ឬកាលៈទេសៈផ្សេងៗ ដែលអំពើទាំងនោះហួសពីសមត្ថភាពរបស់គូភាគី។

**ប្រការ ១៣ ៖ អំពីការបង្កើតកិច្ចសន្យា និងភាសា**

កិច្ចសន្យានេះត្រូវបានបង្កើតឡើងជាភាសាខ្មែរមានចំនួន ០៣ច្បាប់ដើម ដោយភាគី "ក" ទទួលបានចំនួន ០១ច្បាប់ដើម ភាគី "ខ" ទទួលបានចំនួន ០១ច្បាប់ដើម និងអគ្គនាយកដ្ឋានសុខភាសត្វនិងផលិតកម្មសត្វ ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រក្សាទុកចំនួន ០១ច្បាប់ដើម ដែលមានតម្លៃគតិយុត្តស្មើៗគ្នា។

ដើម្បីជាសក្ខីភាពភាគីទាំងពីរត្រូវធ្វើការចុះហត្ថលេខានិងប្រថាប់ត្រាលើកិច្ចសន្យានេះ ។

កិច្ចសន្យានេះធ្វើនៅ................................

ថ្ងៃ......................... ខែ...............ឆ្នាំ..........................ព.ស.................

ត្រូវនឹងថ្ងៃទី..............ខែ................ឆ្នាំ...................

ភាគី "ខ"
**រូបវន្តបុគ្គល ឬនីតិបុគ្គល**
**(ម្ចាស់កសិដ្ឋានចិញ្ចឹមសត្វ)**

ភាគី "ក"
**នាយកដ្ឋានផលិតកម្មសត្វ**
**ឬការិយាល័យផលិតកម្ម និងបសុពេទ្យបាល**

**បានឃើញ និងឯកភាព**
**អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ**
**ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី/ខេត្ត**...............

**កន្លែងតម្កល់ឯកសារ**

- សាលាខេត្តពាក់ព័ន្ធ
- អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- នាយកដ្ឋានផែនការ និងស្ថិតិ
- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
- នាយកដ្ឋាននីតិកម្មកសិកម្ម
- នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តពាក់ព័ន្ធ
- ដូចប្រការ១៣

ស្តីពី "**ចំណាត់ថ្នាក់ខ្នាត បទដ្ឋានបច្ចេកទេស និងនីតិវិធី**
**សម្រាប់ការផ្តល់លិខិតអនុញ្ញាតការចិញ្ចឹមសត្វនិងការបង្កាត់ពូជសត្វ**"

# សំណុំបែបបទ
# សម្រាប់ការស្នើសុំចុះបញ្ជីកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ
# និងគំរូវិញ្ញាបនបត្រចុះបញ្ជីកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ

៣.១- គំរូពាក្យស្នើសុំចុះបញ្ជីកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ ខ្នាតតូច
៣.២- គំរូពាក្យស្នើសុំកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ ខ្នាតមធ្យម និងខ្នាតធំ
៣.៣- គំរូវិញ្ញាបនបត្រចុះបញ្ជីកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ ខ្នាតតូច
៣.៤- គំរូវិញ្ញាបនបត្រចុះបញ្ជីកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ ខ្នាតមធ្យម និងខ្នាតធំ

គំរូទី៣.១

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................. ភេទ............. អាយុ.........ឆ្នាំ ជនជាតិ............ សញ្ជាតិ.............
មុខរបរ/តួនាទី.......................................................................................លេខទូរស័ព្ទ................................
មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.......................ផ្លូវ.......................ក្រុមទី.............ភូមិ/មណ្ឌល.............................
ឃុំ/សង្កាត់.................................ក្រុង/ស្រុក/ខណ្ឌ....................................រាជធានី/ខេត្ត.............................។

**សូមគោរពជូន**

**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី/ខេត្ត**..................

**កម្មវត្ថុ** ៖ សំណើសុំចុះបញ្ជីកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ ខ្នាតតូច

**យោង** ៖ -ព្រះរាជក្រមលេខ នស/រកម/០១១៦/០០៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ

-ប្រកាសលេខ................ប្រក.កសក ចុះថ្ងៃទី.........ខែ..........ឆ្នាំ២០....... ស្តីពីចំណាត់ថ្នាក់ខ្នាតបទដ្ឋានបច្ចេកទេស និងនីតិវិធីសម្រាប់ការផ្តល់លិខិតអនុញ្ញាតការចិញ្ចឹមសត្វនិងការបង្កាត់ពូជសត្វ

-លិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ លេខ........................................
ចុះថ្ងៃទី.........ខែ...........ឆ្នាំ២០...... ចេញដោយ..........................................................។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកប្រធានមន្ទីរ** មេត្តាជ្រាបថា ៖ ខ្ញុំបាទ/នាងខ្ញុំ មានបំណងចុះបញ្ជីកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ ☐គោ-ក្របីយកសាច់, ☐គោ-ក្របីយកទឹកដោះ, ☐សេះ, ☐ជ្រូកសាច់, ☐ជ្រូកពូជ, ☐ពពែ, ☐ចៀម, ☐ស្វា, ☐ទន្សាយ, ☐មាន់យកស៊ុត, ☐មាន់យកសាច់, ☐មាន់ពូជ, ☐ទា, ☐ក្ងួច, ☐ឃ្មុំ, ☐សត្វផ្សេងៗ.........................................................................
ឈ្មោះកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ......................................................................................
មានទីតាំងស្ថិតនៅ ៖ ចំណុច............................ផ្លូវ.................ភូមិ.......................ឃុំ/សង្កាត់.......................
ក្រុង/ស្រុក/ខណ្ឌ................................រាជធានី/ខេត្ត.............................។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកប្រធានមន្ទីរ** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

ថ្ងៃ.............................ខែ............ឆ្នាំ.............ព.ស.២៥......
ធ្វើនៅ............................ថ្ងៃទី..........ខែ..........ឆ្នាំ២០......

**ស្នាមមេដៃស្តាំឬហត្ថលេខា**

គំរូទី៣.២

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................. ភេទ............. អាយុ.........ឆ្នាំ ជនជាតិ............ សញ្ជាតិ.............
មុខរបរ/តួនាទី.................................................................................លេខទូរស័ព្ទ.....................................
មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.......................ផ្លូវ.......................ក្រុមទី.............ភូមិ/មណ្ឌល...........................
ឃុំ/សង្កាត់................................ក្រុង/ស្រុក/ខណ្ឌ....................................រាជធានី/ខេត្ត.................................។

## សូមគោរពជូន
## ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា
## អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

**កម្មវត្ថុ** ៖ សំណើសុំចុះបញ្ជីកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ □ខ្នាតមធ្យម, □ខ្នាតធំ

**យោង** ៖ -ព្រះរាជក្រមលេខ នស/រកម/០១១៦/០០៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ

-ប្រកាសលេខ................ប្រក.កសក ចុះថ្ងៃទី..........ខែ..........ឆ្នាំ២០....... ស្តីពីចំណាត់ថ្នាក់ខ្នាត បទដ្ឋានបច្ចេកទេស និងនីតិវិធីសម្រាប់ការផ្តល់លិខិតអនុញ្ញាតការចិញ្ចឹមសត្វនិងការបង្កាត់ពូជសត្វ

-លិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ លេខ.........................................
ចុះថ្ងៃទី..........ខែ...........ឆ្នាំ២០...... ចេញដោយ.........................................................។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រតិភូ** មេត្តាជ្រាបថា ៖ ខ្ញុំបាទ/នាងខ្ញុំ មានបំណងចុះបញ្ជីកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ □គោ-ក្របីយកសាច់, □គោ-ក្របីយកទឹកដោះ, □សេះ, □ជ្រូកសាច់, □ជ្រូកពូជ, □ពពែ, □ចៀម, □ស្វា, □ទន្សាយ, □មាន់យកស៊ុត, □មាន់យកសាច់, □មាន់ពូជ, □ទា, □ក្រួច, □ឃ្មុំ, □សត្វផ្សេងៗ..........................................................................
ឈ្មោះកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ.......................................................................................
មានទីតាំងស្ថិតនៅ ៖ ចំណុច............................ផ្លូវ..................ភូមិ.....................ឃុំ/សង្កាត់.......................
ក្រុង/ស្រុក/ខណ្ឌ......................................រាជធានី/ខេត្ត................................។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រតិភូ** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

ថ្ងៃ..............................ខែ.............ឆ្នាំ............ព.ស.២៥....
ធ្វើនៅ..........................ថ្ងៃទី.........ខែ............ឆ្នាំ២០....

**ស្នាមមេដៃស្តាំឬហត្ថលេខា**

គំរូទី៣.៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី/ខេត្ត.........

លេខ.....................................មក.វចប

# វិញ្ញាបនបត្រចុះបញ្ជី

## កសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ

| | | |
|---|---|---|
| យោង | ៖ | លិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ លេខ............. ចុះថ្ងៃទី........ ខែ....... ឆ្នាំ២០... |
| ចុះបញ្ជីក្រោមលេខ | ៖ | ...................................................................................................................... |
| ឈ្មោះកសិដ្ឋានចិញ្ចឹមសត្វ | ៖ | ...................................................................................................................... |
| មានទីតាំងស្ថិតនៅ | ៖ | ចំណុច.......................ភូមិ...................ឃុំ.......................ស្រុក..................ខេត្ត.................. |
| ត្រូវបានទទួលស្គាល់ថា | ៖ | **កសិដ្ឋានចិញ្ចឹមសត្វ** *(បញ្ជាក់ពីប្រភេទសត្វ)* **លក្ខណៈពាណិជ្ជកម្ម "ខ្នាតតូច"** |

ស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌ ដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ថ្ងៃ.......................ខែ............ឆ្នាំ..........ព.ស ២៥...

ធ្វើនៅ.......................ថ្ងៃទី.........ខែ...........ឆ្នាំ២០...

**ប្រធានមន្ទីរ**

**វិញ្ញាបនបត្រ* មានសុពលភាពចាប់ពីថ្ងៃចុះហត្ថលេខាដល់ថ្ងៃទី........ ខែ....... ឆ្នាំ.... ហួសរយៈពេលកំណត់នេះត្រូវទុកជាមោឃៈ។

គំរូទី៣.៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ**
លេខ.....................សផស.វចប

# វិញ្ញាបនបត្រចុះបញ្ជី
## កសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ

យោង ៖ លិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ លេខ............ ចុះថ្ងៃទី........ ខែ....... ឆ្នាំ២០...
ចុះបញ្ជីក្រោមលេខ ៖ ..............................................................................................................
ឈ្មោះកសិដ្ឋានចិញ្ចឹមសត្វ ៖ ..............................................................................................................
មានទីតាំងស្ថិតនៅ ៖ ចំណុច.........................ភូមិ.....................ឃុំ.........................ស្រុក...................ខេត្ត....................
ត្រូវបានទទួលស្គាល់ថា ៖ **កសិដ្ឋានចិញ្ចឹមសត្វ** *(បញ្ជាក់ពីប្រភេទសត្វ)* **លក្ខណៈពាណិជ្ជកម្ម □ខ្នាតមធ្យម ឬ □ខ្នាតធំ**

ស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌ ដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ថ្ងៃ........................ខែ............ឆ្នាំ...........ព.ស.២៥...
ធ្វើនៅ........................ថ្ងៃទី.........ខែ...........ឆ្នាំ២០...
**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**
**អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ**

* វិញ្ញាបនបត្រ មានសុពលភាពចាប់ពីថ្ងៃចុះហត្ថលេខាដល់ថ្ងៃទី........ ខែ....... ឆ្នាំ....
ហួសរយៈពេលកំណត់នេះត្រូវទុកជាមោឃៈ។

ឧបសម្ព័ន្ធទី៤ នៃប្រកាសលេខ.........................ប្រក.កសក ចុះថ្ងៃទី............ខែ...............ឆ្នាំ២០១....

ស្តីពី "**ចំណាត់ថ្នាក់ខ្នាត បទដ្ឋានបច្ចេកទេស និងនីតិវិធី សម្រាប់ការផ្តល់លិខិតអនុញ្ញាតការចិញ្ចឹមសត្វនិងការបង្កាត់ពូជសត្វ**"

# សំណុំបែបបទ
# សម្រាប់ការស្នើសុំវិញ្ញាបនបត្របញ្ជាក់
# ការអនុវត្តការចិញ្ចឹមសត្វល្អ ( GAHP )

៤.១- គំរូពាក្យស្នើសុំបញ្ជាក់ការអនុវត្តការចិញ្ចឹមសត្វល្អ (GAHP)

៤.២- គំរូវិញ្ញាបនបបញ្ជាក់ការអនុវត្តការចិញ្ចឹមសត្វល្អ (GAHP)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គំរូទី៤.១**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.......................................... ភេទ.............. អាយុ.........ឆ្នាំ ជនជាតិ............. សញ្ជាតិ.............
មុខរបរ/តួនាទី........................................................................................................លេខទូរស័ព្ទ...............................
មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.........................ផ្លូវ..........................ក្រុមទី...............ភូមិ/មណ្ឌល...................................
ឃុំ/សង្កាត់................................ក្រុង/ស្រុក/ខណ្ឌ.................................រាជធានី/ខេត្ត...................................។

## សូមគោរពជូន
## ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា
## អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

**កម្មវត្ថុ** ៖ សំណើសុំវិញ្ញាបនបត្របញ្ជាក់ការអនុវត្តការចិញ្ចឹមសត្វល្អ (GAHP) សម្រាប់កសិដ្ឋានចិញ្ចឹមសត្វនិង/ឬបង្កាត់ពូជសត្វ។

**យោង** ៖- ព្រះរាជក្រមលេខ នស/រកម/០១១៦/០០៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ
- ប្រកាសលេខ...................ប្រក.កសក ចុះថ្ងៃទី..........ខែ..........ឆ្នាំ២០....... ស្តីពីចំណាត់ថ្នាក់ខ្នាតបទដ្ឋានបច្ចេកទេស និងនីតិវិធីសម្រាប់ការផ្តល់លិខិតអនុញ្ញាតការចិញ្ចឹមសត្វនិងការបង្កាត់ពូជសត្វ
- លិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ លេខ......................................................
ចុះថ្ងៃទី.........ខែ...........ឆ្នាំ២០...... ចេញដោយ.....................................................................។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រតិភូ** មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំ បានការអនុញ្ញាតឲ្យបង្កើតកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ □គោ-ក្របីយកសាច់, □គោ-ក្របីយកទឹកដោះ, □សេះ, □ជ្រូកសាច់, □ជ្រូកពូជ, □ពពែ, □ចៀម, □ស្វា, □ទន្សាយ, □មាន់យកស៊ុត, □មាន់យកសាច់, □មាន់ពូជ, □ទា, □ក្រួច, □ឃ្មុំ, □សត្វផ្សេងៗ.................................................................................................
ឈ្មោះកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ..................................................................................................
មានទីតាំងស្ថិតនៅ ៖ ចំណុច........................................ផ្លូវ............................ភូមិ/មណ្ឌល...............................
ឃុំ/សង្កាត់..................................ក្រុង/ស្រុក/ខណ្ឌ.................................រាជធានី/ខេត្ត........................។

**ឯកសារជូនភ្ជាប់មាន** ៖
-លិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ (ថតចម្លង)...........................................០២ច្បាប់
-កិច្ចសន្យាស្តីពីការគ្រប់គ្រងបច្ចេកទេសកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ (ថតចម្លង).............................០២ច្បាប់
-លិខិតបញ្ជាក់បុគ្គលិកបច្ចេកទេសជំនាញវិទ្យាសាស្ត្រសត្វ ១រូប និងវេជ្ជសាស្ត្រសត្វ ១រូប...........................០២ច្បាប់
-គំនូសប្លង់បច្ចេកទេសកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ (ថតចម្លង).........................................០២ច្បាប់
-បច្ចុប្បន្នភាពផែនការផលិតកម្មសត្វ (ប្រចាំឆ្នាំ ឬ ៥ឆ្នាំ)......................................................០២ច្បាប់

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រតិភូ** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

ថ្ងៃ...........................ខែ...............ឆ្នាំ..............ព.ស.២៥....
ធ្វើនៅ...........................ថ្ងៃទី..........ខែ............ឆ្នាំ២០...

**ហត្ថលេខា/ស្នាមមេដៃស្តាំឬម្រាមដៃ**

គំរូទី៤.២

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
MINISTRY OF AGRICULTURE, FORESTRY AND FISHERIES (MAFF)
**អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ**
GENERAL DIRECTORATE OF ANIMAL HEALTH AND PRODUCTION (GDAHP)
លេខ/No.........................សជស/GAHP

**ព្រះរាជាណាចក្រកម្ពុជា**
KINGDOM OF CAMBODIA
**ជាតិ សាសនា ព្រះមហាក្សត្រ**
NATION RELIGION KING

# វិញ្ញាបនបត្របញ្ជាក់

## ការអនុវត្តការចិញ្ចឹមសត្វល្អ (GAHP)

**CERTIFICATE OF GOOD ANIMAL HUSBANDRY PRACTICE**

**យោង៖**
- ព្រះរាជក្រមលេខ នស/រកម/០១១៦/០០៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ
- ប្រកាសលេខ.................... ប្រក.កសក ចុះថ្ងៃទី..........ខែ..........ឆ្នាំ២០..... របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- លិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វ លេខ................ ចុះថ្ងៃទី........ ខែ....... ឆ្នាំ២០...
- សំណើសុំរបស់សាមីជន/ក្រុមហ៊ុន លេខ........................ចុះថ្ងៃទី............ខែ............ឆ្នាំ២០....

**សូមបញ្ជាក់ថា**

**កសិដ្ឋានចិញ្ចឹមសត្វ** *(បញ្ជាក់ពីប្រភេទសត្វ)* **ក្រុមហ៊ុន**..............
មានទីតាំងស្ថិតនៅភូមិ.............ឃុំ..........ស្រុក..........ខេត្ត................

*បានបំពេញនូវលក្ខខណ្ឌតម្រូវបច្ចេកទេស*

**ការអនុវត្តការចិញ្ចឹមសត្វល្អ (GAHP)**

កាលបរិច្ឆេទទទួលស្គាល់ ៖.................................
កាលបរិច្ឆេទផុតសុពលភាព ៖.................................

**This is to certify that**

**The Animal Farm** *(Type of animal)* **of Company**......
Located at ...............Village, ...................Commune,
............................District, ......................Province.

*Has completed requirement of technical standard*

**GOOD ANIMAL HUSBANDRY PRACTICE (GAHP)**

**Date of Accreditation** :.........................................
**Date of Expiration** :.........................................

ថ្ងៃ.....................ខែ.............ឆ្នាំ................ព.ស...........
រាជធានីភ្នំពេញ ថ្ងៃទី.............ខែ.............ឆ្នាំ................

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**
**អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ**
DIRECTOR GENERAL OF GDAHP